# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ: ០៤៨ ...... អ.ប.វ.ឯ.៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០០៤

## ប្រកាស

ស្តីពី

## ការផ្សព្វផ្សាយជាលក្ខណៈពិជ្ជាជីវៈឯកជនក្នុង

## វិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ៥/សរកម/០៧០៤/០១១ ចុះថ្ងៃទី ១៣-០៧-២០០៤ ដែលប្រកាសអោយប្រើ ច្បាប់ធម្មនុញ្ញបន្ថែម សំរាប់ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥-០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣-១១-២០០០ ប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០២០០/០៣៥ ចុះថ្ងៃទី ០១-០២-២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ១១-០៥-០២ ស្តីពីបែបបទនិងលក្ខខណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យលេខ ៦១ អនក្របក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៣
- បានឃើញប្រកាសលេខ ០២០/០១ អបស/មក ចុះថ្ងៃទី ០៧-០៥-០១ របស់ក្រសួងសុខាភិបាលស្តីពីបែបបទនិងលក្ខខណ្ឌបច្ចេកទេស ក្នុងការស្នើបើក ឬ បិទ សុំកែប្រែទីតាំង ឬប្តូរទីតាំងនៃសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំរេច

ប្រការ១.- ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្ម របស់សេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង



HS

ទីស្តីការក្រសួងសុខាភិបាល, លេខ ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨២២ ០៧៤ / ៨២២ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៧៣

ជំនួយវេជ្ជសាស្ត្រ តាមរយៈ វិទ្យុ-ទូរទស្សន៍-សារពត៌មាន-ទស្សនាវដ្តី-ព្រឹត្តិបត្រវេជ្ជសាស្ត្រ-ប័ណ្ណប្រកាសរូបភាព- សិក្ខាសាលា- ប្រពន្ធ័អេឡិចត្រូនិច- ខិតប័ណ្ណចែកចាយតាមផងផ្ទះ- ការផ្សព្វផ្សាយពាណិជ្ជកម្មដោយប្រើឧបករណ៍បំពងសំឡេងតាមទីសាធារណៈ-រថយន្ត-រោងល្ខោន-រោងភាពយន្ត ផ្សារណាត់ ឬតាមរូបភាព ផ្សេង១ត្រូវហាមឃាត់ដាច់ខាត ។

ប្រការ២,- វិជ្ជាជីវវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ មិនត្រូវបានអនុញ្ញាតអោយយកទៅធ្វើប្រឌិតធ្វើជាមុខជំនួញ ផ្ទាល់ខ្លួនណាមួយឡើយ។ រូបភាពផ្សព្វផ្សាយដោយផ្ទាល់ ឬដោយប្រយោល ដែលបំផ្លើស ខុសការពិត ទាំងអស់ ត្រូវហាមឃាត់ ។

ប្រការ៣,- ហាមឃាត់ការផ្សព្វផ្សាយអំពីរោគសញ្ញាគ្លីនិក នៃជំងឺ និងវិធីព្យាបាលណាមួយ ដែលមានលក្ខណៈបំផ្លើស បោកប្រាស់អតិថិជន ។

ប្រការ៤,- មិនអនុញ្ញាតអោយប្រើប្រាស់ ឈ្មោះមន្ទីរពេទ្យ ឬ គ្លីនិកឯកជន អ្នកឯកទេសល្បី១ ទោះបីជាបរទេសក្តី ឬ ខ្មែរក្តី ក្នុងរូបភាព ក្លែងបន្លំសហការជាមួយ ក្នុងទិសដៅឃោសនាផ្សព្វផ្សាយពាណិជ្ជកម្មឡើយ ។

ប្រការ៥,- បន្ទប់ពិគ្រោះព្យាបាលជំងឺ- បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ធ្មេញ- បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ-បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក-បន្ទប់សោភ័ណ្ឌសល្យសាស្ត្រ មន្ទីរពិសោធន៍ មន្ទីរព្យាបាលជំងឺមាត់ធ្មេញ-មន្ទីរសំរាកព្យាបាល-មន្ទីរសម្ភព-មន្ទីរពហុព្យាបាល និង មុខវិជ្ជាជីវៈប្រហាក់ប្រហែលផ្សេងទៀត អាចដាក់ពាក្យសុំធ្វើការផ្សព្វផ្សាយ បានលុះត្រាតែ ទីតាំងសេវានោះមាន ច្បាប់អនុញ្ញាត ឬបានចុះលេខបញ្ជិការ ព្រមទាំងមានឡូហ្គោសំគាល់ពីក្រសួង សុខាភិបាល ។

ប្រការ៦,- រាល់ការផ្សព្វផ្សាយក្នុងក្របខណ្ឌវិជ្ជាជីវៈដែលមិនប៉ះពាល់ដល់ក្រមសីលធម៌គ្រូពេទ្យ អាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។ ម្ចាស់សេវាឯកជន ដែលមានបំណងផ្សព្វផ្សាយ ត្រូវដាក់ពាក្យស្នើសុំ មកក្រសួងសុខាភិបាល ដោយភ្ជាប់មកជាមួយនូវខ្លឹមសារអត្ថបទ ស្គ្រីបវីដេអូ ឬកាសែតសោតទស្សន៍ និងរូបភាព ដែលពាក់ព័ន្ធ នឹងការផ្សាយ ក្រោយពីបានឆ្លងកាត់ការត្រួតពិនិត្យ ផ្តល់យោបល់ ជាមុន ពីសំណាក់ក្រុមប្រឹក្សា គណៈវិជ្ជាជីវៈនីមួយ១ នៃខេត្ត-ក្រុង ។

ប្រការ៧,- សេវាឯកជនវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដែលមានបំណងផ្សព្វផ្សាយ តាមមធ្យោបាយ អ្វីក៏ដោយ ត្រូវប្រើពាក្យពេចន៍ដោយប្រុងប្រយ័ត្ន និង គិតទៅដល់ ប្រតិកម្ម នៃពាក្យពេចន៍ របស់ខ្លួនចំពោះសាធារណៈជននិងក្រមសីលធម៌គ្រូពេទ្យ ជៀសវាងអំពើឃោសនា លើក

ដំកើងខ្លួន ប្រកួតប្រជែង ដើម្បីផ្តល់រំលំ សេវាកម្មមួយទៀតសំរាប់ មូលហេតុអ្វីមួយ ដែលមិនមែនជាផលប្រយោជន៍សាធារណៈ ។

ប្រការ៨,- ខ្លឹមសារផ្សព្វផ្សាយ ត្រូវមានលក្ខណៈត្រឹមត្រូវ តាមឯកសារវេជ្ជសាស្រ្ត ឱសថសាស្រ្ត ទន្តសាស្រ្ត និងជៀសវាង ការឃោសនាបំផ្លើសប្រាស់ចាកខុសពីខ្លឹមសារ ដែលមានការយល់ព្រមអនុញ្ញាត ពីក្រុម-ប្រឹក្សា គណៈវិជ្ជាជីវនិមួយ១ នៃខេត្ត-ក្រុង និង ពីក្រសួងសុខាភិបាល ។

ប្រការ៩,- អាចអនុញ្ញាតអោយ សុំផ្សព្វផ្សាយបាន គឺ នៅពេលដែលមានការបើកទីតាំងថ្មី ឬ មានការផ្លាស់ប្តូរ ឬ បន្ថែមមុខជំនាញ ផ្លាស់ប្តូរទីតាំង។ អត្ថបទ និងរបៀបផ្សាយត្រូវផ្ញើរទៅក្រុមប្រឹក្សាគណៈវិជ្ជាជីវនិមួយ១ នៃខេត្ត-ក្រុង ពិនិត្យជាមុនសិន ។

ប្រការ១០,- បន្ទាប់ពីបានឆ្លងកាត់ការត្រួតពិនិត្យរួច ក្រសួងសុខាភិបាលអាចអនុញ្ញាតអោយចុះផ្សាយជាសាធារណៈបានគឺ:

១-នាមត្រកូល អាស័យដ្ឋានវិជ្ជាជីវៈ លេខទូរស័ព្ទ និងលេខទូរសារ ថ្ងៃ និងម៉ោងទទួល ពិគ្រោះព្យាបាល ។

២-គុណវុឌ្ឍិ សញ្ញាប័ត្រសិក្សាឯកទេស និងសមត្ថភាពផ្សេង១ ទទួលស្គាល់ដោយ សាកល វិទ្យាល័យ វិទ្យាសាស្រ្តសុខាភិបាល និងគណៈវិជ្ជាជីវនិមួយ១ ដែលមានការទទួលស្គាល់ ពីក្រសួងសុខាភិបាល ។

៣-ស្ថានភាពសេវា និងអ្នកផ្តល់សេវា ចំពោះក្រុមហ៊ុនធានារ៉ាប់រង បើមាន ។

៤-ព្រមទាំងខ្លឹមសារផ្សព្វផ្សាយផ្សេង១ទៀត ដែលមានផលប្រយោជន៍ដល់សង្គមជាតិ ។

ប្រការ១១,- រាល់លិខិតអនុញ្ញាតផ្សព្វផ្សាយ តាមគ្រប់រូបភាព មានសុពលភាពរយៈពេល ៦ ខែ គិតចាប់ ពីថ្ងៃចេញលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ១២,- : ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យ ឃើញថា :

-ខ្លឹមសារផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមអនុញ្ញាតរបស់ក្រសួងសុខាភិបាល

-ឬការផ្សព្វផ្សាយនោះអាចបង្កបាតុភាពមិនល្អផ្សេង១ ។

ប្រការ១៣,- ការប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពី ការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈវេជ្ជសាស្រ្ត អមវេជ្ជសាស្រ្ត និងជំនួយវេជ្ជសាស្រ្ត ។



ﾊ5

ប្រការ១៤.- ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល-អគ្គាធិការដ្ឋាន-នាយកដ្ឋានពាក់ព័ន្ធ-គណៈវិជ្ជាជីវ និមួយៗ នៃខេត្តក្រុង-នាយកដ្ឋានមន្ទីរពេទ្យ និង មន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារៈកិច្ចត្រួតពិនិត្យ តាមដានការអនុវត្តន៍ ប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋ. នុត-សុខុម

កន្លែងទទួល:

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា-រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ (ដើម្បីសហការ)
- សាលាក្រុងភ្នំពេញ និង គ្រប់ខេត្តក្រុង
- ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ
- ដូចប្រការ ១៤
- ឯកសារ-កាលប្បវត្តិ